HONEYCOMB 2/3 (July 2001): 49–53



# God and Money
## Part Three—The Search for True Riches

*Neal YOUNGQUIST*

### The Mad Race

We don't have to look far to find people in a mad race to acquire riches. At times the race becomes very competitive, fueled by a strong desire to increase status and power by possessing more material goods or riches than one's neighbor. This pursuit of riches has its consequences. The quest for riches leads people down the dangerous slide of moral compromise leading eventually to destruction. Soon everything is acceptable for the purpose of acquiring more. Corruption, bribery, gambling, lying, oppressing the poor, and other evil practices lead people—regardless of ethnicity or nationality—blindly on this broad path to ruin.

Is possessing material wealth ungodly? No—there were many in the Bible who lived righteous lives and possessed great wealth. Abraham, Job, and Cornelius are a few examples of those God blessed with wealth. These men and others recognized that God is the source of wealth[1]. They had the strength of character and trust in God to prevent riches from becoming the controlling master of their lives.[2]

---

[1]Deut 8:17,18; Prov 10:22.
[2]Matt 6:24.

| *The Perils of the Race Toward Riches* | |
|---|---|
| Poverty | Proverbs 22:16<br>Proverbs 23:4, 5<br>Proverbs 28:19, 22 |
| Family Troubles | Proverbs 15:27 |
| Turmoil | Proverbs 15:16<br>I Timothy 6:10 |
| Threats | Proverbs 13:8 |
| Untrue Friends | Proverbs 19:4 |
| False Trust | Proverbs 11:28<br>I Timothy 6:17 |
| Harmful Desires | I Timothy 6:9 |

There are those, however, who have fallen prey to the deceit of riches with the clear intention of obtaining riches in their own way and time. Balaam, Achan, Gehazi, and Judas, just to name a few, succumbed to the power of riches to their own demise. They all made riches their god and paid the price for it in the end.

## True Riches

To the surprise of many, material wealth is not all-powerful. It has limitations! Wealth cannot save in the day of judgment,[3] does not last forever,[4] cannot satisfy,[5] and is not a source of happiness.[6] Is it not better to seek after true riches that last forever than chasing after temporal earthly gain? What are these eternal riches that are available to those seeking after God's pleasure?

---

[3]Prov 11:4; Ps 52:5–7.
[4]Prov 27:24; Matt 6:19.
[5]Eccl 5:10.
[6]Eccl 2:26.

## Wisdom

The supreme treasure is wisdom. Throughout the book of Proverbs, the reader is encouraged again and again to search for it with all his or her ability. There was a common saying among the Jews: "Seek that to which other things are necessarily connected." A king once said to his friend, "Ask what you want, and I will give it you." He thought within himself, "If I ask to be made a general I will easily obtain it. I will ask something to which all other things can be added." He then said, "Give me your daughter as my wife." This he did knowing that all the blessings of the kingdom would be added to this gift.[7]



| The Beauty of Wisdom From Proverbs | |
|---|---|
| Incomparable Value | ➪ Proverbs 3:14, 15<br>Proverbs 8:11 |
| Long Life | ➪ Proverbs 3:16 |
| Happiness and Peace | ➪ Proverbs 3:17 |
| Enduring Wealth | ➪ Proverbs 8:18 |
| Sound Judgement | ➪ Proverbs 8:14 |
| Riches and Honor | ➪ Proverbs 3:16 |

Similarly, all the blessings of God are found in wisdom. Finding wisdom is like finding a source of never-ending treasures such as purity, peacefulness, gentleness, submissiveness, compassion, sincerity, fruitfulness, and impartiality.[8] These riches of the heart are priceless, worth far more than mere silver and gold.

Where can these riches of wisdom be found? Job writes that God understands the way to them, and he alone knows where they dwell.[9] The storehouse of wisdom is found in respect,

---

[7]Adam Clarke, *Adam Clarke's Commentary on the New Testament—Electronic Edition* (Indiana: Parsons Technology, 1999), s.v. Matt 6:33.

[8]Jas 3:17.

[9]Job 28:23.

adoration, and obedience to the Lord and his commands. And it can be obtained from God—the master creator and source of wisdom who gives generously to all those who ask without doubting.[10]

## Knowing Christ

Wisdom is also found in knowing Christ, who became for us wisdom from God.[11] Coming into fellowship with God does not only mean the richness of eternal life, but also the opportunity for intimacy with our creator. Paul valued this intimacy so much that he surrendered everything that men count as valuable for the surpassing greatness of knowing Christ.[12] As Christ is revealed to us, we begin to understand the manifold blessings of the Kingdom of God and his supreme power working on our behalf.[13] Like wisdom, knowing Christ requires a persistent dedication to seek him and follow after his commands.

## Contentment

The lust for riches and power was just as strong in the days of the early church as they are today. In the midst of a greedy and corrupt generation, Paul encouraged his student Timothy with a gem of truth that, as usual, turns the world's system upside down: *Godliness with contentment is great gain.*[14] Working in harmony, these twin powers of godly living and a sense of inward sufficiency result in enormous strength and steadfastness.

It was with such astounding qualities that the early saints gladly chose to endure great persecution and loss of possessions rather than indulge in the seducing materialism of the age.[15] With great anticipation and confidence these pilgrims and aliens saw from afar an approaching unshakable Kingdom with better and

---

[10]Jas 1:5-8.
[11]1 Cor 1:30.
[12]Phil 3:8–11.
[13]Eph 1:15-23.
[14]1 Tim 6:16.
[15]Heb 10:32–39.

lasting possessions. They properly appraised the temporal corruptible riches of the world and found it woefully insufficient when compared with the eternal riches of the Kingdom.

## A Choice

Today, God has given us a choice—to build our lives on the true riches of his Kingdom, or to seek after the elusive rewards of materialism. The shifting sands of power, gain, and self-worth are short-lived and will not last the storms of life. Only the one who is supported by the pillars of godly wisdom, intimacy, and contentment will stand forever. The choice is obvious but only fully realized when we cultivate a lifestyle that is pleasing to him and effective in our pursuit of the Kingdom.

សំណុំនិគម ២/៣ (កក្កដា ២០០១): ៥៤-៦០



# ព្រះ និង ប្រាក់

## *ភាគទី ៣: ការស្វែងរកទ្រព្យសម្បត្តិដ៏ពិត*

នៀល យ៉ាំងគ្វីស

### ការប្រជែងគ្នារកស៊ី

យើងមិនចាំបាច់ខំរកមើលមនុស្ស ដែលខំប្រជែងគ្នាក្នុងការរកស៊ីឲ្យមានទ្រព្យសម្បត្តិនោះឡើយ ។ នៅពេលដែលការខំប្រជែងគ្នាក្លាយជាការប្រជែងគ្នាយ៉ាងខ្លាំង ដោយព្រោះការប៉ងប្រាថ្នា ចង់បានឋានៈ និង អំណាចខ្លាំងហួសហេតុពេក គឺដោយចង់មានទ្រព្យសម្បត្តិឲ្យច្រើនជាងអ្នកជិតខាងរបស់ខ្លួន ។ ការខំប្រឹងឲ្យមានទ្រព្យសម្បត្តិច្រើននេះ គឺវាមានផលវិបាករបស់វា ។ ការខំប្រឹងរកទ្រព្យសម្បត្តិនាំឲ្យមនុស្សរអិលធ្លាក់ចូលទៅក្នុងបញ្ហាគ្រោះថ្នាក់ ដែលមិនមានសីលធម៌ មិនសុចរិតទៀងត្រង់ នាំឲ្យអន្តរាយនៅថ្ងៃណាមួយ ។ មិនយូរប៉ុន្មាន អ្វីៗគ្រប់យ៉ាងក្លាយជាការដែលអាចទទួលបាន ដោយក្នុងគោលបំណងចង់បានទ្រព្យសម្បត្តិកាន់តែច្រើនឡើងថែមទៀត ។ អំពើពុករលួយ ការស៊ីសំណូក ល្បែងស៊ីសង ការភូតកុហក ការជិះជាន់អ្នកក្រីក្រ និង ការប្រព្រឹត្តិអាក្រក់ដទៃទៀត នាំឲ្យមនុស្សធ្លាក់ទៅក្នុងផ្លូវ ដែលនាំទៅរកភាពអន្តរាយ មិនថាឡើយអ្នកនោះជាជាតិពន្ធ ឬ ជាតិសាសន៍អ្វីឡើយ ។ តើព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងការមានទ្រព្យសម្បត្តិទេឬ? ទេ មិនមែនទេ មានមនុស្សជា

ច្រើននៅក្នុងព្រះគម្ពីរ ដែលរស់នៅដោយសុចរិត និង មានទ្រព្យសម្បត្តិយ៉ាងច្រើនសម្បើម ។ លោក អ័ប្រាហាម យ៉ូប និង កូនាលាស គឺគ្រាន់តែជាគំរូខ្លះៗនៃមនុស្ស ដែលព្រះជាម្ចាស់ប្រទានពរឲ្យគេមានទ្រព្យសម្បត្តិយ៉ាងច្រើនសន្ធឹក[១] ។ គេមានភាពរឹងប៉ឹងផ្នែកចរិតលក្ខណៈ និងទុកចិត្តព្រះជាម្ចាស់ ដោយមិនបណ្តោយឲ្យទ្រព្យសម្បត្តិនោះគ្រប់គ្រងធ្វើជាម្ចាស់នៃជីវិតរស់នៅរបស់គេឡើយ[២] ។

**ការគ្រោះថ្នាក់ដោយការខំប្រឹងប្រែងឲ្យបានទ្រព្យសម្បត្តិច្រើន**

| | |
|---|---|
| ភាពទ័លក្រ | *សុភាសិត ២២:១៦* |
| | *សុភាសិត ២៣:៤-៥* |
| | *សុភាសិត ២៨:១៩,២២* |
| បញ្ហាគ្រួសារ | *សុភាសិត ១៥:២៧* |
| បញ្ហាច្របូកច្របល់ | *សុភាសិត ១៥:១៦* |
| | *១ធីម៉ូថេ ៦:១០* |
| ការតំរាមកំហែង | *សុភាសិត ១៧:៨* |
| មិត្តសម្លាញ់មិនពិត | *សុភាសិត ១៩:៤* |
| ការទុកចិត្តក្លែងក្លាយ | *សុភាសិត ១១:២៨* |
| | *១ធីម៉ូថេ ៦:១៧* |
| ការប៉ងប្រាថ្នាដែលប្រកបដោយគ្រោះថ្នាក់ | *១ធីម៉ូថេ ៦:៩* |

ទោះបីជាយ៉ាងណា ក៏ដោយមានអ្នក ដែលធ្លាក់ខ្លួនទៅជារំពារ នៃសេចក្តីបោកបញ្ឆោតរបស់ទ្រព្យសម្បត្តិដែលមានបំណងច្បាស់លាស់ក្នុង ការប្រមូលទ្រព្យសម្បត្តិ តាមពេលវេលារបស់គេផ្ទាល់។ បាឡាម អេកាន គេហាស៊ី និងយូដាសនេះគ្រាន់តែជាឈ្មោះខ្លះៗ ដែលព្រមចុះចាញ់ អំណាចនៃទ្រព្យសម្បត្តិ រហូតដល់ទីមរណា ។ គេបានខំប្រមូលទ្រព្យសម្បត្តិយ៉ាង

[១] *លោកុប្បត្តិ ៨:១៧, ១៨; សុភាសិត ១០:២២*

[២] *ម៉ាថាយ ៦:២៤*

មានស្តុកស្តម្ភ ដោយចាត់ទុកទ្រព្យនោះជាព្រះរបស់គេ ហើយគេត្រូវសងថ្លៃចំពោះការខំប្រមូលនោះ នៅពេលចុងបញ្ចប់របស់គេ ។

## ទ្រព្យសម្បត្តិដ៏ពិត

មានមនុស្សជាច្រើនភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលថារបស់ទ្រព្យនោះមិនមានអំណាចគ្រប់យ៉ាងទាំងអស់បានទេ ។ គឺវាមានព្រំដែនកំណត់ ! របស់ទ្រព្យមិនអាចជួយសង្គ្រោះ ឲ្យរួចនៅថ្ងៃជំនុំជំរះបានទេ[៣] មិនស្ថិតស្ថេររហូតឡើយ[៤] មិនអាចធ្វើឲ្យស្កប់ស្កល់ចិត្តបានឡើយ[៥] ហើយក៏មិនមែនជាប្រភពនៃសុភមង្គលនោះដែរ[៦] ។ តើមិនមែនជាការប្រសើរទេឬអី បើយើងស្វែងរកទ្រព្យសម្បត្តិដ៏ពិត ដែលស្ថិតស្ថេរដ៏យូរអង្វែងជាជាង ការដែលខំដេញតាមទ្រព្យសម្បត្តិបណ្តោះអាសន្ន ដែលនៅផែនដីនេះ? តើអ្វីដែលជាសម្បត្តិដ៏នៅអស់កល្បទាំងឡាយនោះ គឺមាននៅក្នុងអស់អ្នកណាដែលស្វែងរកព្រះរាជបំណងរបស់ព្រះជាម្ចាស់មែនទេ?

## គតិបណ្ឌិត

សម្បត្តិទ្រព្យដ៏ប្រសើរបំផុតនោះ គឺគតិបណ្ឌិត ។ នៅក្នុងកណ្ឌគម្ពីរសុភាសិតទាំងមូល គេបានជំរុញលើកទឹកចិត្តម្តងហើយម្តងទៀតឲ្យស្វែងរកគតិបណ្ឌិត ឲ្យអស់ពីសមត្ថភាពរបស់ខ្លួន ។ មានពាក្យស្លោកដែលពួកសាសន៍យូដាបាននិយាយជាធម្មតានោះគឺ: "ចូរ ស្វែងរករបស់អ្វីដែលមានការទាក់ទងគ្នាជាចាំបាច់" ។ មានស្តេចមួយអង្គ បានសួរទៅសម្លាញ់របស់ខ្លួនថា "ចូរសុំអ្វីដែលអ្នកចង់បាន នោះយើងនឹងប្រទាន

---

[៣] សុភាសិត ១១:៤; ទំនុកតម្កើង ៥២:៥-៧

[៤] សុភាសិត ២៧:២៤; ម៉ាថាយ ៦:១៩

[៥] សាស្តា ៥:១០

[៦] សាស្តា ២:២៦



ឲ្យអ្នកឯង" ។ ម្នាក់នោះបានគិតមួយស្របក់ ក្នុងចិត្ត"បើអញសុំធ្វើជាមន្ត្រីធំនោះ អញនឹងបានធ្វើភ្លាមយ៉ាងងាយ ។ អញនឹងសុំអ្វីមួយ ដែលនឹងមានការ ទាក់ទងទៅនឹងការបន្ថែមលើការអ្វីផ្សេងទៀត" ។ បន្ទាប់មកគាត់ក៏បានឆ្លើយថា"ចូរឲ្យបុត្ររបស់ព្រះអង្គ រៀបការនឹងទូលបង្គំ" ។ ការនេះ គាត់បានធ្វើដោយដឹងថា ព្រះពរទាំងឡាយនៃអាណាចក្រនោះ នឹងត្រូវបន្ថែមមក ដល់អំណោយ ដែលគាត់បានសុំនេះឯង[៧] ។

ស្រដៀងគ្នានេះដែរ ព្រះពរទាំងឡាយរបស់ព្រះជាម្ចាស់ គឺមាននៅក្នុងគតិបណ្ឌិត ។ ការស្វែងរកគតិបណ្ឌិត គឺដូចជាការស្វែងរកប្រភពធនធាននៃកំណប់ទ្រព្យ ដែលគ្មានទីបញ្ចប់ ដូចជាភាពបរិសុទ្ធ សេចក្តីសុខសាន្ត ចិត្តសុភាព ការព្រមចុះចូល សេចក្តីមេត្តាករុណា សេចក្តីស្មោះត្រង់ មានផលផ្លែយ៉ាងច្រើន និង ការមិនប្រកាន់បក្សពួក[៨] ។ ទ្រព្យ

---

(7) Adam Clarke, *Adam Clarke's Commentary on the New Testament—Electronic Edition* (Indiana: Technology, 199), s.v. Matt 6:33.
(8) Jas 3:17

សម្បត្តិនៃដួងចិត្តទាំងនេះ គឺមានតម្លៃខ្លាំងណាស់ មានតម្លៃច្រើនជាង ប្រាក់ និង មាស ទៅទៀត ។

តើគេអាចរកទ្រព្យសម្បត្តិនៃគតិបណ្ឌិតទាំងនេះ នៅកន្លែងណាទៅ? លោកយ៉ូប សរសេរថា ព្រះជាម្ចាស់ ទ្រង់យល់ពីរបៀប ដែលគតិបណ្ឌិតធ្វើការយ៉ាងណា ហើយនិងលោកគ្រាន់តែដឹងថា គតិបណ្ឌិតនៅឯណា[៩] ។ ឃ្លាំងនៃគតិបណ្ឌិត គឺគេឃើញនៅក្នុងការគោរព ការកោតសរសើរ និង ការស្តាប់បង្គាប់ដល់ព្រះអម្ចាស់ និង ព្រះរាជបញ្ញត្តិរបស់ព្រះអង្គ ។ យើងអាចទទួលនូវគតិបណ្ឌិតប្រាជ្ញានោះ ពីព្រះជាម្ចាស់ ជាព្រះអាទិករ និង ជាប្រភពនៃប្រាជ្ញា ព្រះអង្គនឹងប្រទានឲ្យយ៉ាងសប្បុរសដល់អស់អ្នកណា ដែលទូលសុំដោយឥតសង្ស័យ[១០] ។

## ការស្គាល់ព្រះគ្រីស្ទ

គេអាចរកឃើញគតិបណ្ឌិតផងដែរ នៅក្នុងការស្គាល់ព្រះគ្រីស្ទ ដែលព្រះអង្គបានក្លាយជា តួនៃគតិបណ្ឌិត សម្រាប់យើងមកពីព្រះជាម្ចាស់[១១] ។ ការប្រកបជិតស្និទ្ធជាមួយព្រះជាម្ចាស់ មិនគ្រាន់តែមានន័យថា យើងមានជីវិតអស់កល្បជានិច្ចទេឡើយ តែជាឱកាសនៃការនៅជិតស្និតជាមួយព្រះអាទិករ របស់យើង ។ លោកប៉ូល ឲ្យតម្លៃចំពោះ ការប្រកបជិតស្និទ្ធនេះខ្លាំងណាស់ ដែលគាត់ព្រមលះបង់ចោលរបស់គ្រប់យ៉ាងដែលមនុស្សទូទៅរាប់ថា មានតម្លៃលើសពីការស្គាល់ព្រះគ្រីស្ទនោះ[១២] ។ នៅពេលដែលព្រះគ្រីស្ទបានសម្តែង អង្គទ្រង់ឲ្យយើងស្គាល់នោះ យើងចាប់ផ្តើមយល់ពីព្រះពរនៃអាណាចក្រព្រះជាច្រើនបែប និង អំណាច

---

[៩] *យ៉ូប ២៨:២៣*

[១០] *យ៉ាកុប ១:៥-៨*

[១១] *១កូរិនថូស ៣:៣០*

[១២] *ភីលីព ៣:៨-១១*

ចេស្តាដ៏ឧត្តមរបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានធ្វើការ ជំនួសយើង[១៣] ។ ដូចគ្នានឹងគតិបណ្ឌិតដែរ ការស្គាល់ព្រះគ្រីស្ទ តម្រូវឲ្យមានការប្តូរផ្តាច់ ដើម្បីស្វែងរកព្រះអង្គ និង ធ្វើតាមព្រះរាជបញ្ញត្តិរបស់ព្រះអង្គ ។

## ការស្កប់ចិត្ត

ការលោភចង់បានទ្រព្យសម្បត្តិ និង អំណាចហួសហេតុ គឺមានក្នុងកាលពីសម័យក្រុមជំនុំសម័យដើម ក៏ដូចគ្នាសម័យឥឡូវនេះដែរ ។ នៅក្នុងចំណោមជំនាន់មនុស្ស ដែលលោភលន់ និង មានអំពើពុករលួយ លោក ប៉ូល យកសេចក្តីពិតដ៏ពិសិដ្ឋលើកទឹកចិត្ត ឲ្យសិស្សរបស់គាត់ឈ្មោះ ធីម៉ូថេ បង្វិលប្រព័ន្ធគ្រប់គ្រងរបស់លោកិយនេះឲ្យដាក់ក្បាលចុះក្រោមគឺៈ ការស្កប់ចិត្ត ដោយស្កប់ចិត្តកោតខ្លាចព្រះ គឺជាការប្រសើរបំផុតក្នុងការចម្រើនបានទ្រព្យសម្បត្តិ[១៤] ។ ការធ្វើការដោយស៊ីសង្វាក់គ្នារវាងអំណាចទាំងពីរនេះ គឺការរស់នៅដោយកោតខ្លាចព្រះមួយ និង ស្កប់ចិត្តមួយ បង្ហាញជាលទ្ធផលនូវកម្លាំងពលំដ៏ខ្លាំងសម្បើម និង ភាពស្មោះត្រង់យ៉ាងសម្បើម ។

គឺដោយមានគុណសម្បត្តិដ៏ចម្លែកអស្ចារ្យបែបនេះ ទើបបានជាពួកបរិសុទ្ធកាលពីជំនាន់ដើម រីករាយក្នុងការជ្រើសរើសយក ដោយអត់ទ្រាំនូវការបៀតបៀន និង ការបាត់បង់នូវទ្រព្យសម្បត្តិយ៉ាងច្រើន ជាជាងព្រមទទួលយកនូវការបណ្តោយឲ្យខ្លួន ធ្លាក់ក្នុងការលួងលោមនៃសម្បត្តិទ្រព្យនៅក្នុងសម័យនេះ[១៥] ។ ដោយមានការពិចារណាជ្រួតជ្រាបពីហេតុការណ៍ជាមុន និង ដោយមានការទុកចិត្តយ៉ាងមុតមាំ ពួកអ្នកបរិសុទ្ធ និង

---

(១៣) *អេភេសូ ១:១៥-២៣*

(១៤) *១ធីម៉ូថេ ៦:១៦*

(១៥) *ហេព្រើ ១០:៣២-៣៩*

គួកនទាំងនេះ បានឃើញពីចម្ងាយនូវការខិតជិតចូលមកដល់នៃអាណាចក្រ ដែលឥតរង្គើ ប្រកបទៅដោយសម្បត្តិទ្រព្យដ៏ប្រសើរ និង គង់វង្សអស់កល្ប ។ ពួកគេបានធ្វើការវាយតម្លៃលើទ្រព្យសម្បត្តិបណ្តោះអាសន្ននៅក្នុងលោកិយ ដែលតែងតែពុករលួយនោះ និង បានយល់ឃើញថាទ្រព្យសម្បត្តិនេះ គឺគ្មានប្រយោជន៍សោះ នៅពេលដែលប្រៀបទៅនឹងសម្បត្តិនៃអាណាចក្រព្រះ ។

## ការជ្រើសរើស

នៅថ្ងៃនេះ ព្រះជាម្ចាស់បានផ្តល់ឲ្យយើងនូវការជ្រើសរើសមួយ គឺថាត្រូវសង់ជីវិតរបស់យើងនៅលើទ្រព្យសម្បត្តិនៃអាណាចក្រ របស់ព្រះអង្គ ឬ ក៏ត្រូវខំដេញតាមទ្រព្យសម្បត្តិបណ្តោះអាសន្ន ដែលជាសម្បត្តិនៅលើលោកិយនេះ ។ អំណាច ការរកស៊ីចំណេញច្រើន និង បុណ្យសក្តិឋានៈ ដែលមិនទៀងទាត់នោះ គឺមិនស្ថិតស្ថេរឡើយ និង មិនធន់ទ្រាំបាននឹងព្យុះនៃជីវិតបានឡើយ ។ អ្នកដែលអាចធន់ទ្រាំបានមានតែអ្នកដែល មានការគាំទ្រពីសរសរដ៏រឹងមាំនៃគតិបណ្ឌិត ការប្រគល់ជិតស្និទ្ធនឹងព្រះជាម្ចាស់ និង ស្កប់ចិត្តនឹងអ្វី ដែលខ្លួនមាន ទើបអាចឈរជាប់នៅបាន ។ ការជ្រើសរើសនោះ គឺច្បាស់លាស់ណាស់ ប៉ុន្តែគ្រាន់តែថាតើយើងយល់ច្បាស់ទេ នៅពេលដែលយើងរៀបចំដំណើរជីវិតរស់នៅដែលគាប់ព្រះហឫទ័យរបស់ព្រះ និង មានប្រសិទ្ធិភាពក្នុងការស្វែងរកអាណាចក្ររបស់ព្រះអង្គ ។